ឆ្នាំ ទី ១៣ លេខ ៣៧ សប្តាហ៍ទី ៣ ថ្ងៃ ទី ១៩ ខែឧសភា ឆ្នាំ ២០១៣ រាជកិច្ច ទំព័រ ៤៣៥៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ ៦.០៤៨ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃ គូលែន-ព្រហ្មទេព ស្ថិតនៅក្នុងឃុំកន្ទួត និងឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ សម្រាប់ផ្តល់ចែកជូនគ្រួសារយោធិនចំនួន ១៧០០គ្រួសារ ក្នុងកងពលតូចអន្តរាគមន៍លេខ៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១ៈ**

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ត្រង់មាត្រា១១ ចំណុច៤ ត្រូវបានកំណត់ទំហំដី ៦ ០៤៨(ប្រាំមួយពាន់ សែសិប ប្រាំបី)ហិកតា ជាតំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងឃុំកន្ទួត និងឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

តំបន់សហគមន៍ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផែនទីនិងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២៖**

ផ្ទៃដីតំបន់សហគមន៍ចំនួន ៦ ០៨៨ហិកតានេះ សម្រាប់ផ្ដល់ចែកជូនគ្រួសារយោធិនចំនួន ១៧០០គ្រួសារ ក្នុងកងពលតូចអន្តរាគមន៍លេខ៨។ រាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ និងការចាត់ចែងដីក្នុងតំបន់សហគមន៍នេះ ត្រូវអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងនីតិវិធីនៃច្បាប់ជាធរមាន។

**មាត្រា៣៖**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ